សហព័ន្ធខ្មែរកម្ពុជាក្រោម
KHMERS KAMPUCHEA-KROM FEDERATION
Asia – Australia – Europe – North America
A member of UNPO & IDBF

P.O. Box 39084 • London • ON • N5Y-5L1 • CANADA. Tel/Fax: (856) 655-3838
http://www.khmerkrom.net • Email: thach.thach@khmerkrom.org

# លិខិតអំពាវនាវ

## ជួយឧបត្ថម្ភព្រះសង្ឃនិងជនរងគ្រោះខ្មែរក្រោម

ស្ថានភាពបច្ចុប្បន្ននៅកម្ពុជាក្រោមនិងកម្ពុជាដែលរដ្ឋអំណាចយួនកុម្មុយនិស្តបានបង្កើនកំលាំងជិះជាន់គាបសង្កត់លើសិទ្ធិសេរីភាពដោយអំណាចផ្តាច់ការយ៉ាងឃោឃៅមកលើប្រជាពលរដ្ឋស្លូតត្រង់ខ្មែរក្រោម។
ព្រះសង្ឃខ្មែរក្រោមត្រូវបានចាប់ផ្សឹករួចដាក់ពន្ធនាគារជាបន្តបន្ទាប់និងបានគំរាមកំហែងទៅលើប្រជាពលរដ្ឋខ្មែរក្រោមស្លូតត្រង់ដោយរឹបអូសយកដីស្រែចំការជាដើម។ នេះជាទង្វើប្រវត្តិសាស្ត្ររបស់រដ្ឋអំណាចយួនគ្រប់ជំនាន់ ក្នុងការកំចាត់បំបាត់តាងនិងរំលាយពូជសាសន៍តាមវិធីធ្វើឲ្យខ្មែរក្រោមអវិជ្ជា ខ្មែរក្រោមក្រ ខ្មែរក្រោមទាល់ច្រក។ល។
ដោយឡែកយួនកុម្មុនិស្តបានសហការជាមួយក្រុមទេព វង្ស នន្ទ ង៉ែតនិងបក្សពួកបានប្រព្រឹត្តនូវអំពើផ្តុយនិងគន្លងព្រះពុទ្ធសាសនាដូចមានការផ្សឹកព្រះសង្ឃខ្មែរក្រោមធ្វើឃាត កំលាំងហឹង្សា ចាប់ជំរឹតដូចករណីយធ្វើឃាតព្រះភិក្ខុ អៀង សុខធៀននិព្រះភិក្ខុ ទឹម សាខន។
ដូចជំរាបនិងប្រគេនដំណឹងខាងលើសហព័ន្ធសូមអំពាវនាវដល់សប្បុរសជនទាំងឡាយមេត្តាជួយធ្វើវិភាគទានដើម្បីជួយដល់ព្រះសង្ឃនិងជនរងគ្រោះព្រមទាំងក្រុមគ្រួសារតាមសម្ថភាពនិងលទ្ធភាពក្នុងការជួយរំលែកទុក្ខមួយ ជួយឈឺឆ្អាលមួយ ជួយការពារព្រះពុទ្ធសាសនាមួយនិងជួយការពារខ្មែរក្រោមឲ្យផុតពីអំពើប្រល័យពូជសាសន៍របស់យួនកុម្មុយនិស្តន៍។

សូមព្រះតេជគុណ លោក លោកស្រីសប្បុរសជនមេត្តាទទួលនូវសេចក្តីរាប់អានដ៏ខ្ពង់ខ្ពស់អំពីខ្ញុំព្រះករុណាខ្ញុំបាទ។
ធ្វើនៅថ្ងៃទី២០ កក្កដា ២០០៧
ទីក្រុងឡុនដុន កាណាដា

ថាច់ ង៉ុក ថាច់
ប្រធានសហព័ន្ធ